**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៧៥៤ សហវ.ប្រក

ថ្ងៃចន្ទ ១៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៩

# ប្រកាស
## ស្ដីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ./.



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្ដីជូនដំណឹងលេខ ១០៥ សជណ.ពហ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្ដីពីការកំណត់កម្រៃសេវាអាកាសចរស៊ីវិល (Civil Aviation Fee - CAF)
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .–**

ត្រូវបានបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ទី តាឃី** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២- | ឯកឧត្តម **ជា អួន** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រលអស) | អនុប្រធាន |
| ៣- | ឯកឧត្តម **អួន ម៉ិនហាក់** | អគ្គនាយករង នៃ កសហវ | អនុប្រធានប្រចាំការ |
| ៤- | លោក **ទ៉ាន់ ចន្ទី** | ប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃ រលអស | សមាជិក |
| ៥- | លោក **ជេន ផាត** | ប្រធាននាយកដ្ឋាន នៃក្រុមប្រឹក្សាជាតិគណនេយ្យ នៃ កសហវ | សមាជិក |
| ៦- | លោក **ធេព វណ្ណាដា** | អនុប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃ កសហវ | សមាជិក |
| ៧- | លោក **ហ៊ត់ ឆានី** | ប្រធានការិយាល័យ នៃនាយកដ្ឋានចំណូលសាធារណៈ នៃ កសហវ | សមាជិក |
| ៨- | លោក **ឆាយ វណ្ណៈ** | ប្រធានការិយាល័យ នៃនាយកដ្ឋានភស្ដុភារ និងហិរញ្ញវត្ថុ នៃ រលអស | សមាជិក |
| ៩- | លោក **គង់ ពិដោរ** | ប្រធានការិយាល័យនៃនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសនៃរលអស | សមាជិក |
| ១០- | កញ្ញា **ហា សុគន្ធា** | មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ នៃ កសហវ | សមាជិក |
| ១១- | លោក **សាន គីមហ៊ាង** | មន្ត្រីនាយកដ្ឋានចំណូលសាធារណៈ នៃ កសហវ | សមាជិក |
| ១២- | លោក **សោម យ៉ាន់សាម៉ូ** | មន្ត្រីនាយកដ្ឋានភស្ដុភារ និងហិរញ្ញវត្ថុ នៃ រលអស | សមាជិក |
| ១៣- | លោក **ទី ទិន្ធ** | មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ នៃ កសហវ | លេខាធិការ |

**ប្រការ២ .–**

ក្រុមការងារមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដែលប្រមូលបានពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ តាមរយៈក្រុមហ៊ុនអាកាសចរណ៍
- ពិនិត្យផ្ទៀងផ្ទាត់ចំណូលដែលប្រមូលបានពីកម្រៃសេវាអាកាសចរស៊ីវិល ជាប្រចាំ

- សហការជាមួយស្ថាប័នពាក់ព័ន្ធ សិក្សាឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយអំពីយន្តការ និងនីតិវិធី ដើម្បីភៀវគរចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ឱ្យអស់សក្តានុពល
- ធ្វើរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ សម្រេច ឬ ផ្តល់អនុសាសន៍ការណែនាំដ៏ខ្ពង់ខ្ពស់។

ទន្ទឹមនឹងនេះ ក្រុមការងារក៏មានសិទ្ធិអញ្ជើញក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ ដែលបាន និងកំពុងធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមប្រជុំតាមការចាំបាច់ ឬ ស្នើសុំផ្តល់ឯកសារពាក់ព័ន្ធនឹងចំនួនភ្ញៀវទេសចរ ដែលធ្វើដំណើរចេញពីអាកាសយានដ្ឋានទាំងអស់។

**ប្រការ៣ .-**

សមាសភាពនៃក្រុមការងារ ដែលមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ឯកឧត្តមប្រធានក្រុមការងារ។ នៅពេលប្រធានក្រុមការងារអវត្តមាន អនុប្រធានក្រុមការងារត្រូវដឹកនាំការប្រជុំតាមកាលបរិច្ឆេទដែលបានកំណត់។

**ប្រការ៤ .-**

ប្រកាសលេខ ១៨៤ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ